ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២១១៨ កសក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម
ចូល លេខ ១២៣
ថ្ងៃទី ១៦.០៣.២៣
បញ្ជូន

# លិខិតអម

**គោរពជូន៖ -ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង**

| ល.រ | រាយមុខលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | -របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែកុម្ភៈ** និងទិសដៅអនុវត្តបន្ត ............................ | ១ច្បាប់ | "ដើម្បីជូនជ្រាប" --------- |

ថ្ងៃសុក្រ ៤រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២៣

**ត.ប.រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គលេខាធិការ**

**ស្រី វុឌ្ឍី**

16-03-23

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្ដីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែកុម្ភៈនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបានចំនួន ៦៨០ ៦៣៩ហ.ត ស្មើនឹង១៣៩,២៧% នៃផែនការចំនួន ៤៨៨ ៧០៨ហ.ត។ វិធានការជួយសង្គ្រោះបន្ទាន់ និងវិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែកុម្ភៈនេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់ ការប្រជុំពិចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២៣ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចក្នុងឆ្នាំ២០២៣ នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្ដាផ្នែក

### ១- លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំង

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៦៨០ ៦៥៦ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៥៨១ហ.ត ស្មើនឹង០,០៩% និងដោយគ្រឿងយន្តចំនួន ៦៨០ ០៧៥ហ.ត ស្មើនឹង៩៩,៩១% លើសឆ្នាំមុន ៤១ ១៨៥ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ១៣ហ.ត លើសឆ្នាំមុន ៨ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៦៨០ ៦៣៩ហ.ត ស្មើនឹង១៣៩,២៧% នៃផែនការចំនួន ៤៨៨ ៧០៨ហ.ត លើសឆ្នាំមុន ៤២ ២៩២ហ.ត។
- ការប្រមូលផលស្រូវប្រាំងសម្រេចចំនួន ៣១៥ ៦០៤ហ.ត ទទួលបរិមាណផលសរុបចំនួន ១ ៤៥៤ ១៣២តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៦០៧តោន/ហ.ត។

#### ១.២ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំង

- ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៣៤ ៣៨១ហ.ត ស្មើនឹង៩១,២៩% នៃផែនការចំនួន ៣៧ ៦៦០ហ.ត លើសឆ្នាំមុន ៦៩៣ហ.ត
- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ១១១ ៤៨៧ហ.ត ស្មើនឹង៩៤,៨២% នៃផែនការចំនួន ១១៧ ៥៨០ហ.ត លើសឆ្នាំមុន ១៦ ៥២៤ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣-២១៧ ៣២(

## ១.៣ ការនាំចេញផលិតផលកសិកម្ម

### ១.៣.១ ការនាំចេញអង្ករ

ការនាំចេញអង្ករក្នុងខែកុម្ភៈ ឆ្នាំ២០២៣ មានចំនួន ៦០ ៥៦៧តោន។ ការនាំចេញអង្ករក្នុងរយៈពេល២ខែ ឆ្នាំ២០២៣ មានចំនួន ៩៧ ៤៦៧តោន។

អង្ករក្រអូបគ្រប់ប្រភេទមានចំនួន ៨៦ ៣៩៦តោន អង្ករសគ្រប់ប្រភេទមានចំនួន ៨ ១៨១តោន និងអង្ករចំហុយ មានចំនួន ២ ៨៩០តោន។

បរិមាណអង្ករនាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ១៩ប្រទេស មានបរិមាណសរុបចំនួន ៣៥ ៣៤៣តោន ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ៤៩ ០៥៦តោន ទិសដៅអាស៊ានចំនួន ២ប្រទេស មានបរិមាណសរុប ចំនួន ៤ ៤០៩តោន និងទិសដៅដទៃទៀតចំនួន ១៥ប្រទេស មានបរិមាណសរុប ៨ ៦៥៩តោន។

ក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៤០ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗ ចំនួន១០ មានរហូតដល់ ៧១ ១១៧តោន និងក្រុមហ៊ុន៣០ដទៃទៀតបាននាំចេញត្រឹមតែ ២៦ ៣៥០តោន។

### ១.៣.២ ការនាំចេញស្រូវ

ការនាំចេញស្រូវក្នុងរយៈពេល២ខែឆ្នាំ២០២៣ មានចំនួន ៨៧១ ៣១៩តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ៤៦៤ ០២៥តោន)។

### ១.៣.៣ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ

ក្នុងរយៈពេល២ខែឆ្នាំ២០២៣ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ មានចំនួន ១ ២០៣ ៧៦១,០៨តោន ក្នុង នោះរួមមាន៖

- ចំណិតដំឡូងមីក្រៀមមានចំនួន ៧២០ ៤៧៨តោន ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ៦៤៩ ៥០០តោន ប្រទេសវៀតណាមចំនួន ៧០ ៩៥០តោន និងប្រទេសចិនចំនួន ២៨តោន
- ដំឡូងមីស្រស់មានចំនួន ១៣១ ៥៥០តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ១១១ ៥៥០តោន និងប្រទេសថៃចំនួន ២០ ០០០តោន
- ម្សៅដំឡូងមីមានចំនួន ៧ ៤៥៥,៣០តោន ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៧ ៤៣០តោន និង ប្រទេសជប៉ុនចំនួន ២៥,៣០តោន
- កាកសំណល់ដំឡូងមីមានចំនួន ៣០ ១៥៤តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ២៣ ១០០តោន ប្រទេសថៃចំនួន ៦ ៦០០តោន និងប្រទេសចិនចំនួន ៤៥៤តោន
- គ្រាប់ស្វាយចន្ទីមានចំនួន ១១៤ ១៩៣,៩៣តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ១១៤ ១៤០,៥៣តោន ប្រទេសជប៉ុនចំនួន ២៧តោន ប្រទេសថៃចំនួន ២០តោន និងប្រទេសកូរ៉េចំនួន ៦,៤០តោន
- គ្រាប់ពោតមានចំនួន ១២ ៨៨១,៣០តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ១២ ២០០តោន កោះតៃវ៉ាន់ចំនួន ៦៧១,៧៨តោន និងប្រទេសកូរ៉េចំនួន ៩,៥២តោន
- គ្រាប់សណ្តែកបាយមានចំនួន ៣ ០០០តោន នាំចេញទៅប្រទេសវៀតណាម
- គ្រាប់សណ្តែកសៀងមានចំនួន ៥ ១០០តោន នាំចេញទៅប្រទេសវៀតណាម
- ផ្លែចេកស្រស់មានចំនួន ៥៩ ១៩៩,៧១តោន ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៥៥ ១៥៩,២១តោន និងប្រទេសវៀតណាមចំនួន ៤ ០៤០,៥០តោន
- ផ្លែស្វាយស្រស់មានចំនួន ២៨ ៧៤០,៣៨តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ២០ ៨៣៣,២៨តោន ប្រទេសថៃចំនួន ៧ ៨៩៦,៣០តោន និងប្រទេសកូរ៉េចំនួន ១០,៨០តោន
- ដំណាប់ស្វាយមានចំនួន ៣ ២០៥,២៩តោន ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ២ ៨៥៨,៦៤តោន ប្រទេសហ្វីលីពីនចំនួន ១៨២,៣៦តោន ប្រទេសន័រវែសចំនួន ៦៤,៨០តោន ប្រទេសថៃចំនួន ៥៦,០២តោន ប្រទេស ជប៉ុនចំនួន ៣២,៣០តោន ចក្រភពអង់គ្លេសចំនួន ៨តោន ប្រទេសកូរ៉េ ១,៦៣តោន ប្រទេសដាណឺម៉ាកចំនួន ១,៥១តោន និងសហរដ្ឋអាមេរិកចំនួន ០,០៣តោន
- ផ្លែមៀនស្រស់មានចំនួន ២ ៤២៨,៤៨តោន នាំចេញទៅប្រទេសចិន

- ដូងប្រេងមានចំនួន ១៤ ៧៧៥តោន ក្នុងនោះនាំចេញទៅប្រទេសឥណ្ឌាចំនួន ១២ ៦០០តោន និងប្រទេសម៉ាឡេស៊ីចំនួន ២ ១៧៥តោន

- ម្រេចមានចំនួន ៤៣០,៥៨តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣៨២,៥០តោន សហរដ្ឋអាមេរិកចំនួន ២៥,៨៧តោន ប្រទេសកូរ៉េចំនួន ១៦,០៩តោន ប្រទេសបារាំងចំនួន ៤,៣៧តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ១,៥៤តោន ប្រទេសសិង្ហបុរីចំនួន ០,១០តោន ប្រទេសជប៉ុនចំនួន ០,០៤២តោន កោះតៃវ៉ាន់ចំនួន ០,០៤តោន ប្រទេសអូស្រ្តាលីចំនួន ០,០៣តោន និងប្រទេសម៉ាឡេស៊ីចំនួន ០,០០២តោន

- បន្លែចម្រុះមានចំនួន ៣៤,៩៣តោន នាំចេញទៅប្រទេសបារាំង

- ផលិតផលចំនួន ៤៧មុខ ផ្សេងទៀតមានចំនួន ៧០ ១៣៤,១៧តោន។

**១.៣.៤ ការប៉ាន់ស្មានតម្លៃនៃការនាំចេញកសិផល**

ការប៉ាន់ស្មានតម្លៃគិតជាទឹកប្រាក់ក្នុងរយៈពេល១ខែឆ្នាំ២០២៣ ដែលទទួលបានពីការនាំចេញកសិផល (ឯកតាតម្លៃផ្អែកតាមវិក្កយបត្ររបស់អ្នកនាំចេញ) មានចំនួន ៧៩០ ៥១១ ៣៧៧,៧៥ដុល្លារអាមេរិក ក្នុងនោះ៖

- ការនាំចេញអង្ករមានចំនួន ៨៣ ៣៣៤ ២៨៥ដុល្លារអាមេរិក
- ការនាំចេញស្រូវមានចំនួន ១៧៥ ១៣៥ ១១៩ដុល្លារអាមេរិក
- ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ៥៣២ ០៤១ ៩៧៣,៧៥ដុល្លារអាមេរិក។

## ២- ផ្នែកផលិតកម្មកៅស៊ូ

**២.១ ផ្ទៃដីកៅស៊ូ**

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ៥៧៨ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៧ ០២០ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩២ ៤០២ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦៥ ១៥៦ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១៥ ៣៣២ហ.ត ស្មើនឹង៧៨% និងផ្ទៃដីថែទាំចំនួន ៨៩ ២៤៦ហ.ត ស្មើនឹង២២%។

**២.២ ផលិតកម្មកៅស៊ូ**

- ផលិតផលជ័រកៅស៊ូក្នុងខែមករា ឆ្នាំ២០២៣ មានចំនួន ៤២ ៧៣៦តោន កើនឡើងចំនួន ៨ ៥៩៨តោន ស្មើនឹង២៥% ធៀបនឹងខែមករា ឆ្នាំ២០២២

- ផលិតផលឈើកៅស៊ូក្នុងខែមករា ឆ្នាំ២០២៣ មានចំនួន ១២០ម$^{៣}$ ។

**២.៣ ការនាំចេញកៅស៊ូ**

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូក្នុងខែមករា ឆ្នាំ២០២៣ មានចំនួន ៤០ ១៥៩តោន កើនឡើងចំនួន ៧ ៦៤០តោន ស្មើនឹង២៣% ធៀបនឹងខែមករា ឆ្នាំ២០២២

- បរិមាណបញ្ចេញលក់ឈើកៅស៊ូក្នុងខែមករា ឆ្នាំ២០២៣ មានចំនួន ៩៥៧ម$^{៣}$។

**២.៤ តម្លៃកៅស៊ូ**

- តម្លៃលក់ជ័រកៅស៊ូគិតជាមធ្យមក្នុងខែមករា ឆ្នាំ២០២៣ គឺ១ ៣៣៥ដុល្លារ/តោន ថយចុះចំនួន ៣៤៦ដុល្លារ/តោន ស្មើនឹង២១% ធៀបនឹងខែមករា ឆ្នាំ២០២២

- តម្លៃលក់ឈើកៅស៊ូគិតជាមធ្យមក្នុងខែមករា ឆ្នាំ២០២៣ គឺ១៥៥ដុល្លារ/ម$^{៣}$

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារ គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៤ ៤០០៛/គ.ក្រ ដល់ ៤ ៩០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ១ ៨០០៛/គ.ក្រ ដល់ ២ ៦២៥៛/គ.ក្រ។

**២.៥ ចំណូលពីការនាំចេញជ័រកៅស៊ូ និងឈើកៅស៊ូ**

- ចំណូលពីការនាំចេញជ័រកៅស៊ូក្នុងខែមករា ឆ្នាំ២០២៣ មានចំនួន ៥៣ ៦២៥ ៨៥៧ដុល្លារ
- ចំណូលពីការនាំចេញឈើកៅស៊ូក្នុងខែមករា ឆ្នាំ២០២៣ មានចំនួន ១៤៨ ៤៦៤ដុល្លារ។

## ៣- ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តសរុបចំនួន ៥៤គ្រឿង និងយានយន្តសរុបចំនួន ៣៥គ្រឿង ជូនក្រុមហ៊ុនចំនួន ៣ក្រុមហ៊ុន គឺក្រុមហ៊ុន ណោង ណា អ៊ិនវេសម៉ិន ឯ.ក ស្ថិតនៅខេត្តមណ្ឌលគិរី ក្រុមហ៊ុន សល សុភា ពាណិជ្ជ និងក្រុមហ៊ុន ធី អេស អិម ដាប់ប៊ែលយូ ឯ.ក ស្ថិតនៅខេត្តស្ទឹងត្រែង

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ២ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ២នាក់ មានឈើហ៊ុបមូលចំនួន ៥៤៩ម$^{៣}$ កូនឈើចំនួន ១០ ០១៧ដើម អុសចម្រុះចំនួន ៧០ស្ទេរ និងជ័រទឹកចំនួន ២៩៦តោន។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- ចុះសិក្សាស្រាវជ្រាវ និងថតរូបសត្វស្លាបទឹកនៅជុំវិញតំបន់បឹងទន្លេសាបភ្នំក្រោម ភូមិចុងឃ្នាស សហគមន៍នេសាទមែកព្រៃ ខេត្តសៀមរាប និងតំបន់វាំមសាព្រែកទាល់ ខេត្តបាត់ដំបង

- ចុះសិក្សាស្រាវជ្រាវ និងប្រមូលសំណាកសត្វល្អិត ស្ថិតនៅខេត្តតាកែវ ដោយរកឃើញប្រភេទសត្វល្អិតសរុបចំនួន ១ ១១០ក្បាល (សត្វល្អិតចំនួន ៦១ប្រភេទ)

- ចុះអនុវត្តគម្រោងអភិរក្សសត្វខ្ទីងក្នុងតំបន់សហគមន៍ព្រៃឈើវាលកន្សែងស្ថិតក្នុងឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ និងបានដំឡើងម៉ាស៊ីនថតរូបស្វ័យប្រវត្តិសរុបបានចំនួន ៦គ្រឿង ដើម្បីធ្វើការថតចាប់យក រូបភាពសកម្មភាពសត្វព្រៃគ្រប់ប្រភេទ អង្កេតតាមដានកត្តាគំរាមកំហែងផ្សេងៗកំពុងកើតមានក្នុងតំបន់សហគមន៍ព្រៃឈើទាំងមូល។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៥ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៦ទីតាំង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង មានស្វាក្តាមសរុបចំនួន ១៤២ ៧៨២ក្បាល ក្នុងនោះ កូនកើតក្នុងខែចំនួន ១ ៦៧៤ក្បាល

- សហការជាមួយខណ្ឌរដ្ឋបាលព្រៃឈើកំពង់ឆ្នាំង កំពង់ចាម និងកំពង់ធំ ដើម្បីចុះពិនិត្យផ្ទៀងផ្ទាត់ចំនួនសត្វស្វាក្តាមនៅកសិដ្ឋានចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមរបស់ក្រុមហ៊ុន អូរៀន ខេម ខេត្តកំពង់ឆ្នាំង និងក្រុមហ៊ុន ស៊ីន នីផុន ប៊ីអូមេឌីខល ឡាបូរ៉ែតថូរី (ខេមបូឌា) ខេត្តកំពង់ចាម និងក្រុមហ៊ុន ខេអេហ្វ (ខេមបូឌា) ខេត្តកំពង់ធំ

- កំពុងថែរក្សាសត្វព្រៃចំនួន ១ ៧៣៩ក្បាល (បក្សីចំនួន ៥៤ប្រភេទ ថនិកសត្វចំនួន ៤៤ប្រភេទ និងល្មូនចំនួន ១៥ប្រភេទ)

- សង្គ្រោះសត្វព្រៃថ្មីចំនួន ៧១ក្បាល ព្យាបាលចំនួន ៣៦ក្បាល និងស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញចំនួន ៨៦ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ២៦នាក់ ចុះល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៥ គឺអារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង១,៥គីឡូម៉ែត្រ និងអនាម័យព្រៃ២ ៤៥០ម៉ែត្រការ៉េ។

### ៣.៤ ការងារដាំដើមឈើ

- ចុះពិនិត្យទីតាំងសមស្របសម្រាប់ត្រៀមរៀបចំប្រារព្ធពិធីរុក្ខទិវា៩ កក្កដា ឆ្នាំ២០២៣ នៅក្នុងខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម និងខេត្តត្បូងឃ្មុំ ក្នុងនោះ ទីតាំងដីសមស្របស្ថិតនៅស្ថានីយដាំឈើម្សៅ ក្រដាស ហ៊ុន សែន មានក ក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ៨០៧ហ.ត ក្នុងនោះ ចម្ការពូជឈើទំហំ១០៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ៣៩ហ.ត ចម្ការឈើដាំទំហំ៦២៤ហ.ត និងចម្ការរុក្ខទិវា៩ កក្កដា សរុបទំហំ៤០ហ.ត ស្ថិតក្នុងខេត្តកំពត ព្រះសីហនុ កំពង់ធំ កំពង់ឆ្នាំង បាត់ដំបង ក្រចេះ និងខេត្តព្រះវិហារ

- បណ្តុះកូនឈើសរុបចំនួន ២៣ ៥៨០ដើម នៅថ្នាលបណ្តុះកូនឈើចំនួន ៦ទីតាំង

- រៀបចំកាត់សម្អាត និងថែទាំដើមមេអាកាស្យាចំនួន ៥ ០០០ដើម និងប្រេងខ្យល់ចំនួន ៣០ ០០០ដើម ដើម្បីត្រៀមរៀបចំកាត់ត្រួយបណ្តុះពិសោធន៍

- ការដាំឈើវិស័យឯកជន ក្រុមហ៊ុនដៃគូសហការ និងលក្ខណៈគ្រួសារឈូសឆាយសម្អាតដីដាំឈើទំហំ ១ ៦៣៩ហ.ត ដីចម្ការអាកាស្យាទំហំ៤០០ហ.ត និងបណ្តុះកូនប្រេងខ្យល់ចំនួន ២០០ ០០០ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន ៣៣ករណី ក្នុងនោះ សំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន ៦ករណី និងសំណុំរឿងបទល្មើសព្រៃឈើបញ្ជូនទៅតុលាការចំនួន ២៧ករណី

- វត្ថុតាងបទល្មើសព្រៃឈើចាប់យាត់ និងដកហូត រួមមាន៖ ឈើអារមានចំនួន ៥៥ម៣ សត្វព្រៃចម្រុះប្រភេទមានចំនួន ២២០ក្បាល និងសាច់ព្រៃទម្ងន់ ៤៧គីឡូក្រាម ផ្ទៃដីព្រៃឈើកាប់រានទំហំ ៤៣០ហ.ត និងអនុផលព្រៃឈើ ព្រមទាំងឧបករណ៍សម្ភារមួយចំនួនទៀត

- វត្ថុតាងសត្វព្រៃ និងសំណាកសត្វព្រៃប្រមូលតាមរយៈក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តសរុបចំនួន ៤៣ករណី (តាមរយៈប្រគល់-ទទួលចំនួន ៣៨ករណី ធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពចំនួន ២ករណី ដកហូតលែង និងបំផ្លាញចោលចំនួន ៣ករណី រួមមាន៖ សត្វព្រៃរស់ចម្រុះប្រភេទចំនួន ១៣៣ក្បាល សត្វព្រៃងាប់ចម្រុះប្រភេទមានចំនួន ២៨ក្បាល។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំពន្យាររោងសិប្បកម្មចំនួន ១កន្លែងស្ថិតនៅខេត្តបាត់ដំបង
- ចុះពិនិត្យសំណើសុំពន្យាររោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ១កន្លែងស្ថិតនៅក្នុងខេត្តស្វាយរៀង
- ក្រុមហ៊ុនចំនួន ១នាំចេញផលិតផលរានទេវតាទៅក្រៅប្រទេសមានចំនួន ៣៨ម៣
- ក្រុមហ៊ុនចំនួន ១នាំចូលឈើកែច្នៃមានចំនួន ១៧២ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីវិស័យព្រៃឈើសរុបចំនួន ២៩៤ ២៣១ ១០០រៀល និង ៥៥ ២១៦,៦៧ដុល្លារ។

## ៤- ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ

### ៤.១ ការងារផលិតកម្មសត្វ

បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្មូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។ ចុះពិនិត្យ និងវាយតម្លៃទីតាំងស្នើសុំបង្កើតកសិដ្ឋានចិញ្ចឹមជ្រូកពូជ ជ្រូកសាច់ មាន់សាច់ មាន់យកស៊ុត មាន់ពូជ ស្វា គោ និងសេះ ជាប្រភេទកសិដ្ឋានខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ បានចំនួន ១០កសិដ្ឋាននៅខេត្តសៀមរាប ត្បូងឃ្មុំ កំពង់ចាម កំពង់ធំ និងខេត្តកំពង់ស្ពឺ ដែលកសិដ្ឋាននីមួយៗមានឡជីវឧស្ម័ន។

### ៤.២ ការងារសុខភាពសត្វ

#### ៤.២.១ លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ

ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលសត្វសរុបបានចំនួន ៣៩ករណី ក្នុងនោះបង្ក្រាបបទល្មើសបាន១ករណី។ រាជធានី-ខេត្តចំនួន២៥បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំ

វ៉ាក់សាំងបង្ការមេរោគចំនួន ១៨ ០៥២លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។

៤.២.២ ការងារផ្សព្វផ្សាយបច្ចេកទេស

- ចុះឃោសនាផ្សព្វផ្សាយស្តីពីជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន៣
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន១។

៤.២.៣ ការងារនីតិកម្ម និងវិវាទ

- កំពុងប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

- កំពុងប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋាន បច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ

- ចុះពិនិត្យតាមដានការអនុវត្តច្បាប់វិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្តាខេត្តចំនួន២។

### ៤.៣ ការងារស្រាវជ្រាវ

៤.៣.១ ការងារស្រាវជ្រាវផលិតកម្ម

បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១២៩ក្បាល។

៤.៣.២ ការងារស្រាវជ្រាវសុខភាពសត្វ

ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាន និងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ១ ០០៤វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) និងជំងឺដុំពកស្បែកគោ ក្របី (LSD)។ វត្ថុវិភាគមានប្រភពមកពីភូមិពពេល ឃុំពពេល ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ និងមកពីភូមិព្រៃហៀវ ឃុំគោកពោធិ៍ ស្រុកបុរីជលសារ ខេត្តតាកែវ វិជ្ជមានជំងឺដុំពកស្បែកគោក្របី (LSDV)។ វត្ថុវិភាគមានប្រភពមកពីភូមិសំរោង ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប និងមកពីភូមិអូររអាម ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី វិជ្ជមានជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។ វត្ថុវិភាគយកពីបក្សីមកពីភូមិរលាំង ឃុំលិច ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង មានមនុស្សស្លាប់តាមការយកសំណាកមកវិភាគឃើញថាវិជ្ជមានមេរោគជំងឺផ្តាសាយបក្សី (H5N1)។

## ៥- ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

៥.១.១ នេសាទទឹកសាប

- ជាយត្រីសម្រេចបានចំនួន ៨៦០តោន ស្មើនឹង៨,៦០% នៃផែនការចំនួន ១០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២២ កើនឡើងចំនួន ២១០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៨ ៣០០តោន សរុបរយៈពេល២ខែចំនួន ៤៣ ៤០០តោន ស្មើនឹង១៤,៤៧% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២២ កើនឡើងចំនួន ២១ ៩០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ២ ២០០តោន សរុបរយៈពេល២ខែចំនួន ៥ ៣០០តោន ស្មើនឹង៣,៧៩% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២២ ថយចុះចំនួន ៥០០តោន។

៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១៦ ៥១០តោន សរុបរយៈពេល២ខែចំនួន ២៩ ០១០តោន ស្មើនឹង២២,៣២% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបខែកុម្ភៈឆ្នាំ២០២២ កើនឡើងចំនួន ១២ ៦១០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ២៧ ៩០០តោន សរុបរយៈពេល២ខែចំនួន ៤៨ ២០០តោន ស្មើនឹង១៣,៣៩% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២២ កើនឡើងចំនួន ៤២ ២៩០តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ២៤ ៩០០ក្បាល សរុបរយៈពេល២ខែចំនួន ៤៩ ៦០០ក្បាល ស្មើនឹង ១៦,៥៣% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២២ កើនឡើងចំនួន ២៩ ២០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ១៤ ២០០ ០០០កូន សរុបរយៈពេល២ខែចំនួន ២៦ ២០០ ០០០កូន ស្មើនឹង ៨,៧៣%នៃផែនការចំនួន ៣០០ ០០០ ០០០កូន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២២ ថយចុះចំនួនប្រមាណ ៨ ៩៥០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៥ ៣០០តោន សរុបរយៈពេល២ខែចំនួន ៨ ៤០០តោន ស្មើនឹង១៤% នៃផែនការចំនួន ៦០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២២ ថយចុះចំនួន ៤០០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១ ៤០០តោន សរុបរយៈពេល២ខែចំនួន ២ ១២០តោន ស្មើនឹង ២១,២០% នៃផែនការចំនួន ១០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២២ ថយចុះចំនួន ២៣០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៨ ០០០ ០០០លីត្រ សរុបរយៈពេល២ខែចំនួន ១០ ៨០០ ០០០លីត្រ ស្មើនឹង ២១,៦០% នៃផែនការចំនួន ៥០ ០០០ ០០០លីត្រ ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២២ កើនឡើងចំនួន ៣០០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ១៧៨ករណី ប្រៀបធៀបឆ្នាំ២០២២ ថយចុះចំនួន ៧៣ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១៥៤ករណី និងសមុទ្រចំនួន ២៤ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ៣តោន សរុបរយៈពេល២ខែចំនួន ១២៣តោន ស្មើនឹង១,៧៦% នៃផែនការចំនួន ៧ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២២ ថយចុះចំនួន ២៨៣តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ១៤០តោន ស្មើនឹង១៤% នៃផែនការចំនួន ១ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២២ កើនឡើងចំនួន ៩៩តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ១៤ ៥៣៨ ៥០០រៀល សរុបរយៈពេល២ខែចំនួន ១៤៨ ០១៧ ៤៨៨រៀល ស្មើនឹង៣៩,៩៥% នៃផែនការចំនួន ៣៧០ ៥០០ ០០០រៀល ប្រៀបធៀបឆ្នាំ២០២២ កើនឡើងចំនួន ២៣ ២៤៩ ៦១៣រៀល។

## ៦- ផ្នែកអគ្គាធិការដ្ឋាន

- ស្រាវជ្រាវព័ត៌មានតាមបណ្ដាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៧៣ករណី លើវិស័យព្រៃឈើ ២៥ករណី ជលផល២០ករណី សុខភាពសត្វនិងផលិតកម្មសត្វ៥ករណី កៅស៊ូ១ករណី ក្សេត្រសាស្ត្រ១ករណី និង វិស័យផ្សេងៗ២១ករណី

- ចូលរួមប្រជុំចំនួន ៨លើក និងចូលរួមពិធីផ្សេងៗ១លើក។

## ៧- ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ១ ០០២ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៣៨៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៤៣៨ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៨១ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៨០៨ច្បាប់ ចេញប្រកាស សេចក្ដីសម្រេច និងសារាចរចំនួន ៥៣ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៩ច្បាប់

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំ ដើម្បីក្ដាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការងារសន្តិសុខសណ្ដាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈ

គេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨- ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៥ ៨៨៣នាក់ (ស្រី១ ៤៦៨នាក់ ស្មើនឹង២៤,៩៥%) រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩៨១នាក់ (ស្រី៨៦៦នាក់ ស្មើនឹង២៩,០៥%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩០២នាក់ (ស្រី៦០២នាក់ ស្មើនឹង២០,៧៤%)
- រៀបចំប្រកាស ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន០៣នាក់
- រៀបចំប្រកាស ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការទៅក្រៅក្រសួងចំនួន០១នាក់
- រៀបចំប្រកាស ស្តីពីការលុបឈ្មោះមន្ត្រីរាជការដែលបានទទួលមរណភាពចំនួន០២នាក់
- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកជូនមន្ត្រីរាជការសរុបចំនួន ១៥នាក់ (ស្រី ១៤នាក់) ក្នុងនោះច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន១០នាក់ និងច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន០៥នាក់ (ស្រី០៤នាក់)
- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ១៥៨នាក់ (ស្រី៤៧នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមចំនួន ១៥៤នាក់ (ស្រី៤៦នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសចំនួន ៤នាក់ (ស្រី១នាក់)។

## ៩- ផ្នែកផែនការ និងស្ថិតិ

- ធ្វើលិខិតស្នើសុំរៀបចំគម្រោងសម្រាប់បញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ឆ្នាំ២០២៤-២០២៦
- ចុះប្រមូលព័ត៌មានស្តីពីស្ថានភាពវិស័យកសិកម្ម ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២៤-២០២៨ នៅខេត្តកំពង់ធំ និងខេត្តសៀមរាប
- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងសប្តាហ៍រៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តទាំង២៥
- ចុះពិនិត្យ និងតាមដានការចុះស្រង់ទិន្នន័យតម្លៃទីផ្សារកសិកម្មនៅខេត្តកំពង់ស្ពឺ កោះកុង កែប ព្រះសីហនុ ក្រចេះ មណ្ឌលគិរី បាត់ដំបង និងខេត្តប៉ៃលិន
- ចុះប្រមូលព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្មនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង និងខេត្តព្រៃវែង។

## ១០- ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) សរុបទឹកប្រាក់ចំនួន ៧៦៤លានរៀល
- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ៦ ២៧២លានរៀល
- ទទួលឥណទានធានាចំណាយ និងរៀបចំឯកសារដេញថ្លៃ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីដំណើរការអនុវត្តកិច្ចលទ្ធកម្មលើការផ្គត់ផ្គង់សម្ភារបរិក្ខារបសុពេទ្យ សម្ភារបរិក្ខារសម្រាប់សត្តឃាតដ្ឋានគំរូ ថ្នាំចាក់ការពារ និងថ្នាំព្យាបាលសត្វប្រចាំឆមាសទី១ ឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងការផ្គត់ផ្គង់ប្រេងឥន្ធនៈប្រើប្រាស់ប្រចាំឆ្នាំ២០២៣
- រៀបចំសំណើសុំគោលការណ៍ធានាចំណាយឥណទានថវិកាជំពូក២១ (គម្រោងវិនិយោគផ្ទាល់) ចំនួន ១៥ ០០០ ០០០ ០០០ (ដប់ប្រាំបីលានរៀលគត់) និងថវិកាបុរេប្រទានចំនួន៤០% សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅតាមបណ្តាសហគមន៍កសិកម្មក្នុងខេត្តគោលដៅសម្រាប់ឆ្នាំ២០២៣។

## ១១- ផ្នែកសវនកម្មផ្ទៃក្នុង

- បានរៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង ផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២៣ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣

- រៀបចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសទី១ M2 ប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ។

## ១២- ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ចូលរួមសិក្ខាសាលា១លើកក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី និងសិក្ខាសាលា១លើក ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស

- រៀបចំលិខិតឆ្លើយតបទៅស្ថានទូតឥណ្ឌាស្តីពីសំណើសុំក្រុមហ៊ុនឥណ្ឌាបញ្ជូនសំណើផ្តល់សេវាកម្មប្រឹក្សានៅក្នុងគម្រោង Agricultural Value Chain Competitiveness and Safety Enhancement

- សម្របសម្រួលជាមួយអង្គភាពជំនាញពីការសុំផ្តល់យោបល់លើសមាសធាតុដែលស្នើកែសម្រួល និងដាក់បញ្ចូលថ្មីនៅក្នុងការចរចាជំទ្បើង ATIGA

- សម្របសម្រួលរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តសកម្មភាពរបស់យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម២០១៩-២០២៣។

## ១៣- ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៣ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១០ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មចំនួន ៧ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្មចំនួន ៥ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ២ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៩ក្រុមហ៊ុន សរុបចំនួន ៧៣សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- ពិនិត្យ និងផ្តល់មតិលើសំណើសុំគោលការណ៍ផ្សព្វផ្សាយធ្វើសិក្ខាសាលាបណ្តុះបណ្តាលដល់អាជីវកររលក់សម្ភារកសិកម្ម និងកសិករ អំពីរបៀបប្រើប្រាស់ផលិតផលថ្នាំកសិកម្ម និងជីកសិកម្មប្រកបដោយសុវត្ថិភាពខ្ពស់តាមរយៈការធ្វើស្រែបង្ហាញ ស្ថានីយវិទ្យុ និងទូរទស្សន៍នៅតាមបណ្តារាជធានី-ខេត្ត ជូនក្រុមហ៊ុនដៃគូអភិវឌ្ឍន៍កសិកម្ម ឯ.ក។

### ១៣.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យក្រុមហ៊ុនប្រកាសប្រតិវេទន៍នាំចូលថ្នាំកសិកម្ម ជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយដល់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១១ក្រុមហ៊ុន

- ចុះត្រួតពិនិត្យវាយតម្លៃឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១១ក្រុមហ៊ុន។

## ១៤- ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- តាមដាន និងដកស្រង់ព័ត៌មានពាក់ព័ន្ធនឹងវិស័យកសិកម្មពីប្រព័ន្ធផ្សព្វផ្សាយនានាក្នុងព្រះរាជាណាចក្រកម្ពុជាសរុបចំនួន ៤៨៩ព័ត៌មាន

- ថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- ចុះតាមដាន និងពង្រឹងការប្រើប្រាស់គេហទំព័ររបស់មន្ទីរ និងប្រមូលធាតុចូលសម្រាប់បង្កើតកម្មវិធីទូរស័ព្ទនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ

- សម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ និងតាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១

- បណ្ណាល័យកសិកម្មទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្ដី ដែលទទួលបានពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ៦ក្បាល/ច្បាប់។

## ១៥- ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការណ៍ស្ដីពីបច្ចេកទេសចិញ្ចឹមបង្កង ភ្ញាស់កូនបង្កងលក់ បច្ចេកទេសចិញ្ចឹមមាន់ ភ្ញាស់កូនមាន់លក់ និងការដាំដុះបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់

- បានចុះទៅថត Video បទយកការណ៍ចំនួន ១ប្រធានបទ

- បានធ្វើការផលិត Video និងចាក់ផ្សាយឡើងវិញចំនួន ២ប្រធានបទ

- បានផលិត Video នាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទ

- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៦ដើម្បីចាក់ផ្សាយ។

## ១៦- ផ្នែកកសិ-ឧស្សាហកម្ម

- អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មចំនួន ៨កិច្ចសន្យា រួមមាន៖ ខេត្តឧត្តរមានជ័យ២កិច្ចសន្យា កំពង់ឆ្នាំង ១កិច្ចសន្យា និងខេត្តបន្ទាយមានជ័យ៥កិច្ចសន្យា

- ចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយស្ដីពីការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូចទៅទីផ្សារ តាមរយៈផលិតកម្មកសិកម្ម តាមកិច្ចសន្យានៅខេត្តឧត្តរមានជ័យ

- ចុះបណ្ដុះបណ្ដាលកសិករស្ដីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តរតនគិរី

- ចុះបណ្ដុះបណ្ដាលកសិករស្ដីពីបច្ចេកទេសក្រោយប្រមូលនៃផលិតផលកសិកម្មនៅខេត្តពោធិ៍សាត់

- ចុះបណ្ដុះបណ្ដាលកសិករស្ដីពីការលើកកម្ពស់ស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្មនៅខេត្តមណ្ឌលគិរី

- រៀបចំសំណាកប្រហុកចំនួន ៦ប្រភេទ ដើម្បីវិភាគបាក់តេរីបង្កគ្រោះថ្នាក់មានដូចជា សាល់ម៉ូណេឡា អ៊ីកូឡាយ ពពួកផ្សិត បាក់តេរីសរុប និងអ៊ីនធីរ៉ូបាក់ទេរីហៃស

- រៀបចំសំណាកម្រេចត្រី ដើម្បីវិភាគ អាហ្វ្លាតុកស៊ីន និងលោហៈធ្ងន់ (អាសេនិច បារត កាដ្យូម និងសំណ)។

## ១៧- ការស្រាវជ្រាវ ការអប់រំ និងការបណ្ដុះបណ្ដាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានកំពុងធ្វើផលិតកម្មគ្រាប់ពូជគ្រើចំប៉ុស៧០ មកដល់ពេលនេះស្ថិតក្នុងតំណាក់កាលស្រូវកំណកំណើតគួរ

- ចុះត្រួតពិនិត្យការងារពិសោធន៍នៅខេត្តព្រះវិហារ

- ចុះប្រមូលសំណាកសត្វល្អិតលើដំណាំស្រូវ និងឪឡឹកនៅខេត្តព្រៃវែង

- ចុះរៀបចំ និងប្រមូលទិន្នន័យពិសោធន៍នៅខេត្តតាកែវ

- ចុះទស្សនកិច្ចពិសោធន៍របស់ក្រុមការងារគម្រោង SMC-75 នៅខេត្តតាកែវ

- ចុះពិនិត្យពិសោធន៍ និងជួបសាកសួរព័ត៌មានស្ដីពីផលិតកម្មដំណាំបន្លែជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅខេត្តកំពត។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២៣ សរុបចំនួន ៣ ១៤៤នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្ដម

- មហាវិទ្យាល័យទាំងអស់បានរៀបចំពិធីការពារសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- ចុះអនុស្សរណៈយោគយល់ (MOU) រវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងក្រុមហ៊ុន ស៊ី ជេ ធី ធី គ្រេឌីង ស្ដីពីការបើកវគ្គបណ្ដុះបណ្ដាលភាសាជប៉ុន និងផ្ដល់ឱកាសការងារនៅប្រទេសជប៉ុន

- ធ្វើបទបង្ហាញអំពីការផលិតជីសរីរាង្គ និងផលិតផលផ្សេងៗដោយប្រើប្រាស់បច្ចេកវិទ្យាផលិតកម្មគ្មានកាកសំណល់ (Zero Waste Agriculture Technology)

- រៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីការបង្កាត់គោសិប្បនិម្មិត ដោយសហការជាមួយក្រុមហ៊ុន BP CATTLE BREED។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២៣ សរុបចំនួន ១ ២២៣នាក់ (ស្រី៥០៤នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូ ដើម្បីជាប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងមន្ត្រីដោយការសិក្សាស្រាវជ្រាវផ្តោតលើៈ ត្រី បង្កង បង្គា មាន់ ទា ពពែ ក្របី គោទឹកដោះ បន្លែ ផ្កា ឫស្សី ស្រូវ ចេក ស្វាយចន្ទី កាកាវ វ៉ានីឡា ស្តៅ អាហារ ថ្នាំសត្វល្អិត និងដី

- សហប្រតិបត្តិការសំខាន់ៗរួមមានការបណ្តុះជាលិការុក្ខជាតិ អាក្វាពោនិក (ប្រព័ន្ធវារីវប្បកម្ម) ការកែច្នៃស្វាយចន្ទី ការផលិតមេ្សៅឫស្សី ការចិញ្ចឹមគោទឹកដោះ ការពិសោធដំណាំជប៉ុន និងការសរសេរសៀវភៅសម្រាប់ការបណ្តុះបណ្តាលរបស់វិទ្យាស្ថាន។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២៣ សរុបចំនួន ៥០៤នាក់ (ស្រី១៧០នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម កេ្សត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើការចម្រាញ់ប្រេងរុក្ខជាតិដូចជា ស្លឹកគ្រៃ ស្លឹកក្រូចសើច និងម្រេច

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- តាមដាន ស្រង់ វិភាគទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ សរុបចំនួន ៦២ពិសោធន៍

- ថែទាំកូនកៅស៊ូ Tissue Culture Plant ចំនួន ២ ៥០០កូន ដែលទទួលមកពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន (RRI-CATAS)

- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យជ័រកៅស៊ូតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍

- ជំរឿនកូនកៅស៊ូងាប់ និងរស់ នៅចម្ការដាំឆ្នាំ២០២០ ដល់ឆ្នាំ២០២២

- រៀបចំកិច្ចប្រជុំពិភាក្សាស្តីពីសេចក្តីព្រាងអនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០២៣-២០២៥

- ត្រួតពិនិត្យការកែច្នៃកៅស៊ូសន្លឹកនៅក្នុងរោងចក្រឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស

- រៀបចំឯកសារបណ្តឹងតវ៉ា (Complaint) និងការងារមិនប្រក្រតី (Nonconforming work) តាមបទដ្ឋានស្តង់ដារសម្រាប់ត្រៀមស្នើសុំ ISO/IEC 17025: 2017

- ចុះត្រួតពិនិត្យ និងវាយតម្លៃរោងចក្ររបស់ក្រុមហ៊ុន សុកហ៊ីន ខូ.,អិលធីឌី នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដែលស្នើសុំបន្តសុពលភាពបញ្ជិកាវោងចក្រឡើងវិញ។

## III- សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបានចំនួន ៦៨០ ៦៣៩ហ.ត ស្មើនឹង១៣៩,២៧% នៃផែនការចំនួន ៤៨៨ ៧០៨ហ.ត និងការប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន ៣១៥ ៦០៤ហ.ត ទទួលបរិមាណផល

សរុបចំនួន ១ ៤៥៤ ១៣២តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៦០៧តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសមាសភាពចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។

ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- **ទិសដៅអនុវត្តបន្ត**

### **១- ផ្នែកដាំដុះ**

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្ម
- បន្តពង្រឹងការងារត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិ និងតាមតម្រូវការនៃប្រទេសនាំចូល ក្នុងគោលបំណងជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា
- ស្រាវជ្រាវឯកសារបច្ចេកទេស និងរៀបចំជាសៀវភៅបច្ចេកទេសស្តីពីស្តង់ដារពូជដំណាំនៃប្រភេទពូជដំណាំអទិភាពដូចជាដំឡូងមី ស្វាយចន្ទី ម្រេច មៀនប៉ៃលិន ទុរេន និងដំណាំបន្លែ
- ស្រាវជ្រាវឯកសារបច្ចេកទេស និងរៀបចំជាសៀវភៅបច្ចេកទេសស្តីពីពិធីសារពិសោធន៍វាយតម្លៃសម្តែងកម្មនៃពូជដំណាំនៅទីវាលដើម្បីធ្វើអាជីវកម្ម ពិសោធន៍វាយតម្លៃ DUS និង VCU សម្រាប់ប្រភេទដំណាំជាអទិភាពដូចជាស្រូវ ពោត ដំឡូងមី សណ្តែកបាយ ស្វាយ ស្វាយចន្ទី ម្រេច និងដំណាំបន្លែ
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### **២- ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ**

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដាន

លើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាត់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តបណ្តុះបណ្តាលបច្ចេកទេសពិឃាតសត្វប្រកបដោយមនុស្សធម៌ដល់មន្ត្រីបសុពេទ្យ និងអាជីវករពិឃាតសត្វ

- ត្រៀមលក្ខណៈចុះអនុវត្តវិធានការបសុព្យាបាលកន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ជំងឺដុំពកស្បែកគោ ក្របី (LSD) និងជំងឺឆ្លងសត្វផ្សេងៗ

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ។

### ៣- ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឱ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹង លេខ១៣៤៨ សជណ.កធ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីរំលោភយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

### ៤- ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការសហគមន៍នេសាទគ្មានបទល្មើសជលផល។

### ៥- ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃ សុក្រ ៤ រោច ខែ ផល្គុន ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**